**ជំពូកទី ៥**

# គមខ្នងពីកំណើត (Spina Bifida)

## តើជំងឺនេះជាអ្វី?



ជំងឺគមខ្នងពីកំណើត (គេអាចហៅថារោគរលាកស្រោមខួរ) គឺជាការពិការភាពដែលបណ្តាល មកពីការលូតលាស់យ៉ាងយឺតតាំងពីកុមារមិនទាន់កើត។ វាបានកើតឡើងនៅពេលដែលឆ្អឹងខ្នងខ្លះៗមិនគ្របជិតកណ្តាលបំពង់**សរសៃប្រសាទ**។ ជាលទ្ធផលកន្លែងទន់នៅខាងឆ្វេងមិនត្រូវបានការពារ ដែលអាចប៉ោងឡើងតាមស្បែកដូចជាពកឡើងជាំ។ ដុំពកសរសៃប្រសាទនេះ ត្រូវគ្របដណ្តប់ដោយស្រទាប់យ៉ាងស្តើង(ភ្នាស) ដែលអាចជ្រាបសារធាតុរាវចេញពីពួរឆ្អឹងខ្នង និងខួរក្បាល។ **គ្មាននរណាម្នាក់ដឹងថាតើអ្វីដែលបណ្តាលឱ្យកើតបែបនេះនោះទេ**។ ប៉ុន្តែមានទារកម្នាក់ក្នុងចំណោមទារក ២៥០ ទៅ ៥០០ នាក់ ដែលកើតមកមានជំងឺគមខ្នងពីកំណើត។

## មូលហេតុដែលបណ្តាលឱ្យកើតជំងឺគមខ្នងពីកំណើត

- **គ្រោះថ្នាក់ខ្លាំង** គ្មានការវះកាត់ដុំពកសរសៃប្រសាទពីដំបូងនោះទេ វាតែងធ្វើឱ្យឆ្លងរាលដាល ហើយធ្វើឱ្យ កុមារស្លាប់ដោយសារជំងឺរលាកស្រោមខួរ។



- **ការខ្សោយសាច់ដុំ** និង **បាត់បង់អារម្មណ៍**។ ជើង និងប្រអប់ជើងអាចត្រូវធ្វើឱ្យស្វិតសាច់ដុំហើយគ្មាន ឬមានអារម្មណ៍តិចតួចប៉ុណ្ណោះ។
- **ត្រគាក** ម្ខាង ឬទាំងសងខាងអាចតាំងសន្លាក់



- **ប្រអប់ជើង** អាចបត់ចុះក្រោម និងទាញចូលក្នុង ឬឡើងលើហើយងាកចេញក្រៅ
- ប្រសិនបើពិការភាពនេះ ទាក់ទងខ្លាំងទៅឆ្អឹងខ្នង (មើលទំព័របន្ទាប់) អាចមាន*សាច់ដុំកន្ត្រាក់* ជើង និងប្រអប់ជើង។
- **ខ្សោយប្រព័ន្ធបញ្ចេញទឹកនោម និងពោះវៀន**។ ក្មេងអាចមិនមានអារម្មណ៍កាលណាវានោម ឬជុះ។ ពេលណាវាធំបន្តិច វាមិនអាចរិវត្តការបញ្ចេញនេះបានទេ ហើយវានឹងនោម ឬជុះដោយមិនដឹងខ្លួន។

- **ក្បាលធំ** " ជំងឺក្បាលធំ " មានន័យថា មានទឹកនៅក្នុងខួរក្បាល មានកុមារដែលកើតជំងឺគមខ្នងពីកំណើត ៤ នាក់ ក្នុងចំណោម ៥ នាក់ មានការលូតលាស់ជាធម្មតា។ ទឹកដែលមាននៅក្នុងខួរក្បាល មិនអាចហូរជាធម្មតាទៅក្នុងខួរឆ្អឹងខ្នងបាន ដូច្នេះវាប្រមែប្រមូល និងដាក់សម្ពាធទៅក្នុងខួរក្បាល និងគ្រោងឆ្អឹង។ ទោះបីជាក្បាលរបស់កុមារ អាចមើលទៅធម្មតាពីកំណើតក៏ពិតមែន ប៉ុន្តែបន្តិចម្តងៗវាឡើងប៉ោងដោយបណ្តាលមកពីទឹកដូចរូបភាពនេះ។




- **ការបំផ្លាញប្រព័ន្ធខួរក្បាល** បើពុំមានការវះកាត់នៅពេលដំបូង ដើម្បីកាត់បន្ថយសម្ពាធទឹកក្នុងក្បាលទេ (ជូនកាលទោះជាមានការវះកាត់ក៏ដោយ) កុមារមួយចំនួនអាចពិការភ្នែក ខូចខួរក្បាលមានលក្ខណៈប្រកាច់ (ប្រកាច់ឆ្កួតជ្រូក សូមមើលទំព័រ ៥៧) ឬវិវត្តន៍ទៅរកជំងឺខូចខួរក្បាល (សូមមើលជំពូកទី ២)

## បញ្ហាដែលអាចនឹងកើតឡើងនៅពេលកុមារធំពេញវ័យៈ









- របួសប្រអប់ជើង កុមារដែលអាចដើរបានប៉ុន្តែស្ពឹកនៅលើប្រអប់ជើងដែលបញ្ហានេះអាចក្លាយជាដំបៅ ឬរបួស។ ប្រសិនបើមានការធ្វេសប្រហែសទាំងនេះនឹងនាំទៅរកការរបួសធ្ងន់ធ្ងរលើសាច់ដុំ ឆ្អឹង និងខូចទ្រង់ទ្រាយ ឬបាត់បង់ប្រអប់រជើង។

## តើកុមារដែលកើតមកគមខ្នងពីកំណើត វិវិត្តន៍យ៉ាងណានៅពេលអនាគត?



នេះគឺសំខាន់ទៅលើផលប៉ះពាល់របស់វា តើធ្ងន់ធ្ងរយ៉ាងណាបន្ទាប់មកទៀត គឺពឹងផ្អែកទៅលើការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការថែទាំទូទៅ ហើយចុងក្រោយគឺពឹងផ្អែកលើការបណ្តុះបណ្តាលជាពិសេស ហើយពឹងផ្អែកលើការគាំទ្រពីក្រុមគ្រួសារ និងសហគមន៍។

កំរិតធ្ងន់ធ្ងរនៃការប៉ះពាល់លើផ្នែកខ្នង គឺវានាំឱ្យខូចខួរឆ្អឹងខ្នងយ៉ាងធ្ងន់ធ្ងរខ្លាំងណាស់ ហើយវាបណ្តាលទៅជាការកំរើកអវយវៈលែងរួច និងបណ្តាលឱ្យមានបញ្ហាជាច្រើនទៀត។ ប្រសិនបើក្បាលហោមប៉ោង( swollen ) ឱកាសរបស់កុមារកាន់តែពិបាកខ្លាំង។ បញ្ហានេះត្រូវប្រើថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ ទោះជាក្រុមគ្រួសារមានជីវភាពល្អក៏ដោយ។ ការវះកាត់ដើម្បីបង្ហូរទឹកចេញពីក្បាល គឺក្រោយមកជួនកាលមានការរលាក ឬរបួស។ ដូច្នេះវាតំរូវអោយមានការវះកាត់ច្រើនដងផងដែរ។ ថ្វីបើមានការថែទាំផ្នែកវេជ្ជសាស្ត្របានល្អក៏ដោយ យ៉ាងហោចណាស់កុមារម្នាក់ក្នុងចំណោមកុមារ ៤ ឬ ៥នាក់ កើតមកមានជំងឺគមខ្នងពីកំណើតយ៉ាងធ្ងន់ធ្ងរ ហើយស្លាប់ក្នុងរយៈពេលខែ ឬឆ្នាំទីមួយនៃជីវិតរបស់គេ។

ទោះជាយ៉ាងណាក៏ដោយ កុមារដែលមានការប៉ះពាល់តិចនៅលើខ្នង កុមាររូបនោះអាចមានបញ្ហាតិចតួចទៅលើការកំរើកលែងរួច ហើយកុមារមានឱកាសល្អសំរាប់ការរស់នៅពេញមួយជីវិត និងប្រកបដោយភាពសប្បាយរីករាយ។ ក្រោមការគាំទ្រពីក្រុមគ្រួសារ និងសហគមន៍ កុមារដែលមានជំងឺគមខ្នងពីកំណើតភាគច្រើន បានទៅសាលារៀន រៀនធ្វើការងារជាច្រើនប្រភេទ រៀបការគូស្រករ និងមានកូន។

ជាទូទៅកុមារទាំងនេះមានការយឺតយ៉ាវ ក្នុងការរៀននូវជំនាញជាមូលដ្ឋានសំរាប់ការថែទាំដោយម្ចាស់ការ (ដូចជាស្លៀកពាក់ ហូបអាហារ ទៅបន្ទប់ទឹកជាដើម ) ប៉ុន្តែគេអាចធ្វើបានខ្លះ ដោយភាពពិការរបស់គេ។ នេះក៏ដោយសារ ឪពុកម្តាយមានការទំរើសហួសហេតុពេក ហើយធ្វើអ្វីៗអោយពួកគេ។ ជាការសំខាន់នោះ ឪពុកម្តាយត្រូវជួយពួកគេអោយចេះធ្វើការងារជាច្រើនដោយខ្លួនគេផ្ទាល់។

## តើកុមារមានជំងឺគមខ្នងពីកំណើត មានឱកាសយ៉ាងណាក្នុងការដើរ?

នេះវាអាស្រ័យទៅលើកត្តាជាច្រើន។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការប៉ះពាល់ច្រើនទៅលើឆ្អឹងជំនី គឺធ្វើអោយកុមារលែងកំរើកអវយវៈរួចដែលនេះនឹងអាចកើតមាន។ រូបភាពខាងក្រោមនេះ បង្ហាញនូវលទ្ធភាពដែលកុមារអាចដើរបាន អាស្រ័យទៅដោយការប៉ះពាល់ផ្សេងៗ។ កន្លែងឆ្នូតៗលើរូបភាពបង្ហាញអំពីផ្នែកនៃរាងកាយ ដែលប៉ះពាល់ដោយការកំរើកអវយវៈលែងរួច និងបាត់បង់នូវការដឹងដោយអារម្មណ៍។



## ការថែទាំកុមារគមខ្នងពីកំណើត

មុនវះកាត់ ក្រោយវះកាត់



ការថែទាំការប៉ះពាល់នៅពេលមាន "ថង់នៃសរសៃប្រសាទ " នៅលើឆ្អឹងជំនីនៃទារកដែលទើបនឹងកើត ឱកាសនៃការរស់នៅមានលក្ខណៈប្រសើរ ប្រសិនបើគេទទួលការវះកាត់ ក្រោយពីរយៈពេលពីរឬបីសប្តាហ៍មក ការវះកាត់ត្រូវធ្វើទៅលើសាច់ដុំ និងស្បែក។ បើពុំមានការវះកាត់ទេ នឹងជួបនូវការគ្រោះថ្នាក់ខ្លាំងដោយសាររបួស និងការប៉ះពាល់ដល់ខួរក្បាលកុមារ ប្រហែលជានឹងមិនអាចរស់នៅយូរទេ។

ចំពោះកុមារដែលមិនបានទទួលការវះកាត់ ចូរព្យាយាម ការពារថង់ សរសៃប្រសាទ ដូច្នេះបន្ទះដ៏ស្តើងដែលគ្របលើនោះ មិនអាចបង្កជារបួសឬបែកចេញពីគ្នាទេ។ ( ប្រសិនបើវា បែកចេញពីគ្នា ការរលាកស្រោមខួរអាចកើតឡើងបាន) ។

វិធីមួយក្នុងការការពារថង់ដោយធ្វើសង្រែកពាក់ ឬថង់ដោយក្រណាត់ ឬកៅស៊ូទន់ៗ ហើយចងវាដូច្នេះវាព័ទ្ធជុំវិញថង់នោះ។ សូមកុំអោយសង្រែក ឬក្រណាត់ប៉ះនឹងថង់នោះ។

**ជំងឺក្បាលធំ:** សំខាន់ត្រូវវាស់វែងនូវរង្វាស់ទំហំជុំវិញក្បាលរបស់កុមារនៅពេលកើត និងបន្ទាប់មកមួយសប្តាហ៍ម្តង ឬច្រើនជាងនេះ។ ប្រសិនបើទំហំរីកខុសធម្មតា ឬប្រសិនបើអ្នកសំគាល់ថាក្បាលហើមខ្លាំង នោះកុមារប្រហែលជាមានជំងឺក្បាលធំ។

**សរសៃ ខួរក្បាលទៅកាន់បេះដូង** **សរសៃ ខួរក្បាលទៅកាន់ពោះ**




ការវះកាត់ដែលហៅថា " ចោះរន្ធបង្ហូរ " ត្រូវធ្វើឡើងមុនពេលសម្ពាធទឹកក្នុងខួរក្បាល បណ្តាលអោយមានការបំផ្លាញខ្លាំង។ បំពង់បង្ហូរ គឺរត់ចេញពីរន្ធពេញទៅដោយទឹកក្នុងខួរក្បាលទៅច្រកចូលនៃបេះដូង ឬទៅពោះវៀន ( ប្រហោងពោះ) ។ វិធីនេះទឹកបន្ថែមហូរចេញពីខួរក្បាល។

ពុំមែនកុមារគ្រប់រូប ដែលមានអត្តសញ្ញាណដំបូងនៃជំងឺក្បាលធំ តំរូវអោយធ្វើការវះកាត់នោះទេ។ ប្រសិនបើក្បាលមិនហើមធំទេ ហើយបញ្ឈប់ការរីកធំយ៉ាងឆាប់រហ័សនោះ វាអាចមានលក្ខណៈប្រសើរឡើងដោយឯកឯង។

***ចូរប្រយ័ត្ន:*** "ចោះរន្ធបង្ហូរ" មិនផ្តល់នូវលទ្ធផលល្អជារឿយៗទេ។ ទោះមានការវះកាត់ក៏ដោយ កុមារជំងឺក្បាលធំ ១ នាក់ក្នុងចំណោម ៥ នាក់ អាចស្លាប់មុនអាយុ ៧ ឆ្នាំ ហើយជាងពាក់កណ្តាល ពួកគេមានជំងឺខូចខួរក្បាល។ កុមារផ្សេងទៀត ជាកុមារឆ្លាត ប៉ុន្តែទោះជាយ៉ាងណា ពួកគេនឹងវិវត្តន៍ទៅភាពធម្មតា។ មុនពេលសំរេចចិត្តធ្វើការវះកាត់ ត្រូវទទួលដំបូន្មានពីអ្នកជំនាញ ២ ឬ ៣ នាក់។

***ចំណាំ :*** យើងទទួលស្គាល់ថា សំរាប់គ្រួសារច្រើននាក់ ដូចដែលបានរៀបរាប់នៅទីនេះ ការវះកាត់ នឹងមិនអាចធ្វើទៅបានទេ លើកលែងតែមន្ទីរពេទ្យដែលផ្តល់សេវាកម្មដោយឥតគិតថ្លៃ ព្រោះការវះកាត់នេះមានតម្លៃថ្លៃណាស់។ មុនពេលសំរេចចិត្ត ធ្វើការវះកាត់គួរពិចារណាទៅលើចំនុចមួយចំនួនដូចជា :

- តើអនាគតរបស់កុមារទៅជាយ៉ាងណានៅពេលពួកគេនៅមានជីវិត? តើពួកគេទទួលការឈឺចាប់ខ្លាំងដែរឬទេ ឬតើពួកគេមានឱកាសរស់នៅដោយការសប្បាយរីករាយ និងពេញលេញដែរឬទេ ប្រសិនបើពួកគេមានលទ្ធភាពខ្លះនោះ?
- ប្រសិនបើក្រុមគ្រួសារចំណាយលុយកាក់ច្រើនទៅលើការវះកាត់ និងទៅលើការថែទាំកុមារជារៀងរាល់ថ្ងៃ តើនេះនឹងប៉ះពាល់ទៅដល់សុខភាព និងសុខុមាលភាពរបស់កូនផ្សេងទៀត នៅក្នុងគ្រួសារដែរឬទេ?

ជាបញ្ចប់ មុនពេលសំរេចចិត្តធ្វើការវះកាត់ សំខាន់ត្រូវពិចារណាយ៉ាងល្អិតល្អន់ តើវានឹងប៉ះពាល់ដល់ជីវិតរស់នៅសំរាប់កុមារ និងគ្រួសារដែរឬទេ?

## ការគ្រប់គ្រងប្លោកនោម និងពោះវៀន

កុមារដែលមានជំងឺគមខ្នងពីកំណើត និងមិនវិវត្តទៅរកការគ្រប់គ្រងដូចគ្នាដូចជា (ការគ្រប់គ្រងប្លោកនោម) និងចល័តទៅរក (ការគ្រប់គ្រងពោះវៀន) ដូចកុមារផ្សេងទៀតដែរ។ កុមារអាចបណ្តាលទៅជានោមទាស់ ឬនៅពេលនាងធំពេញវ័យឡើង នាងអាចបន្តសំអាតប្លោកនោម ឬពោះវៀន ដោយពុំមានប្រាប់មុន នោះប្រហែលជាមិនដឹង ឬមិនមានអារម្មណ៍ឡើយ។ វិធីតាមក្បួនខ្នាតនៃការបង្ហឹកប្រើប្រាស់បន្ទប់ទឹក នឹងមិនមានប្រសិទ្ធភាពទេ។ សូមកុំជេរ ឬស្តីបន្ទោស ចំពោះគ្រោះថ្នាក់ដែលកើតឡើង។

***ចូរប្រយ័ត្ន*** : កុមារដែលគមខ្នងពីកំណើតខ្លះ ប្លោកនោម មិនបានសំអាតល្អទេ។ នេះគឺគ្រោះថ្នាក់បំផុត ពីព្រោះទឹកនោមមាននៅក្នុងប្លោកនោមជាយូរថ្ងៃ មេរោគនឹងកើតឡើងហើយនាំទៅរកការប៉ះពាល់ដល់ប្លោកនោម ឬគ្រលាន។ ហើយកុមារខ្លះ ការប៉ះពាល់បែបនេះ គឺជាទូទៅបណ្តាលអោយគ្រោះថ្នាក់ដល់អាយុជីវិត។






ម្តាយត្រូវដឹងថា ប្លោកនោមពេញស្ទាបវាថ្នមៗអោយគេនោម ។ប្រសិនបើមិនចេញទេម្តាយត្រូវរុញថ្នមៗនៅលើប្លោកនោម ដើម្បីអោយទឹកនោមហូរចេញ។



បន្ទាប់មកកុមារខ្លះះអាចដឹងថាគេត្រូវសំអាតប្លោកនោមរបស់គេដោយការយំ រមៀលពីលើសើច ឬកណ្តាស់។ កុមារខ្លះទៀតរៀនធ្វើដោយសង្កត់ពោះប៉ុន្តែវាអាចគ្រោះថ្នាក់ផងដែរ។



កុមារខ្លះ អាចត្រូវការប្រើ " បំពង់បូម " ឬបំពង់ជ័រ ដើម្បីបញ្ចេញទឹកនោមមកក្រៅ។ ចាប់ពីអាយុ ៥ ឆ្នាំ ទើបពួកគេអាចរៀនធ្វើការបូមចេញដោយខ្លួនគេបាន។

ក្មេងស្រីជារឿយៗ ត្រូវការសំអាតប្លោកនោមជាទៀងទាត់ជាមួយនឹងបំពង់បូម ហើយប្រហែលត្រូវប្រើកន្ទបទឹកនោម (ក្រណាត់នោម) ដើម្បីផ្ទុកទឹកនោមបញ្ចេញវាចេញក្នុងពេលណាមួយ។



ចំពោះក្មេងស្រី កញ្ចក់អាចជួយមើលឃើញរន្ធទឹកនោម។



នៅពេលធំពេញវ័យឡើងក្មេងប្រុសនឹងប្រើស្រោមអនាម័យដែលភ្ជាប់ទៅនឹងថង់ផ្ទុកទឹកនោម។



កុមារភាពច្រើនដែលគមខ្នងពីកំណើត អាចត្រូវបានគេជួយថែទាំទាំងប្លោកនោម និងពោះវៀនដូច្នេះពួកគេអាចរក្សាបាននូវសុខភាពល្អ មានអនាម័យ និងស្ងួតជានិច្ច។ បន្ទាប់មកពួកគេអាចទៅសាលារៀន និងធ្វើការងារជាច្រើននៅក្រៅផ្ទះ ដោយមានជំនឿពេញលេញ។ ដូច្នេះសំខាន់គឺថាបុគ្គលិកស្តារលទ្ធភាព និងសមាជិកក្នុងគ្រួសារ ជួយកុមារទៅលើកម្មវិធីសំអាតប្លោកនោម និងពោះវៀន។

ពតិមានសំខាន់អំពីបញ្ហាទឹកនោម ពោះវៀន ការបង្ការ និងការព្យាបាលផលប៉ះពាល់ទៅលើទឹកនោម។ បញ្ជាក់ដើម្បីឱ្យប្រាកដ សូមសិក្សាលើជំពូកនេះ។

## ការបង្ការ និងកែខៃការគាំងសន្ទាក់

កុមារមួយចំនួនគមខ្ទងពីកំណើតនឹងវិវត្តទៅរកការគាំងសន្ទាក់ នេះក៏ព្រោះតែសាច់ដុំមិនស្មើគ្នា (សូមមើលទំព័រ ៧៨) ឬមិនកើតឡើងជារឿយៗនោះទេ ហើយដោយសារវារឹងគាំង(សាច់ដុំតឹងណែនខុសធម្មតា)។ ការគាំងសន្ទាក់ជាទូទៅវិវត្តទៅរកប្រអប់ជើង ត្រគាក និងជង្គង់។ លំហាត់ប្រាណសាច់ដុំ និងលាតសន្ទឹង ដូចដែលបានពិភាក្សាអាចជួយបង្ការ និងកែខៃការគាំងសន្ទាក់ដំបូង។

> ***ចូរប្រយ័ត្ន :*** ការលំហាត់លាតសន្ទឹងតែមួយគត់ ទៅលើភាពតឹងណែនពិបាកបត់ចុះឡើង ឬចលនាសាច់ដុំជាប់ៗដោយកំណត់ ( range of motion )។ នៅពេលដែលកន្លែងបត់មានលក្ខណះទន់ **មិនត្រូវពត់លាត ខ្លាំងពេកទេ** នៅត្រង់កន្លែងដែលពត់ច្រើនដងនោះ។ ឧទាហរណ៍ :
>
> ប្រសិនបើប្រអប់ជើងរឹងដូចនេះ
>
> 
>
> សូមធ្វើចលនាបន្តិចម្តងៗដោយលើកប្រអប់ជើងឡើងលើ។
>
> ត្រឹមត្រូវ
>
> 
>
> ប៉ុន្តែប្រសិនបើប្រអប់ជើងទន់ឫងឡើងលើខុសពីធម្មតា
>
> 
>
> ចូរជៀសវាងការធ្វើចលនាដោយការលាតអោយខ្លាំងជាងមុន
>
> មិនត្រឹមត្រូវ
>
> 

ដោយសារកុមារគមខ្ទងពីកំណើត មានសាច់ដុំខ្លាំងសំខាន់បត់ ជាជាងការតំរង់ត្រគៀកធ្វើបែបនេះនឹងអាចឈានទៅរកការ **គាំងសន្ទាក់ត្រគៀក**។

ដូចកុមាររូបនេះ ធ្វើចលនាតំរង់ និងដេកផ្កាប់លើក្បាលពោះអាចជួយបាន។




ដូចគ្នានេះផងដែរ អាចធ្វើការធានាបានដោយប្រើឧបករណ៍ជំនួយសំរាប់ដើរដែលអាចជួយកែលំអ នេះវាប្រសើរជាងការបង្កើនការគាំងសន្ទាក់។



ឧបករណ៍ដើរដែលធ្វើអំពីដែកដ៏ថ្លៃនេះធ្វើអោយកុមារដែលគមខ្ទងពីកំណើតដើរដោយមានការបត់នៃត្រគាក។ វាអាចធ្វើអោយត្រគាកគាំងសន្ទាក់និងពុំអាចដើរដោយគ្មានឧបករណ៍ជំនួយក្នុងការដើរ



នៅពេលកុមារឬរទៅដើរជាមួយនឹងបង្កាន់ដៃពីរស្របគ្នាដែលធ្វើឡើងសំរួលទៅតាមកំពស់ត្រឹមត្រូវ វាដើរបានត្រង់ល្អ។ នេះជួយបង្ការការគាំងសន្ទាក់និងបង្កើនទូវលទ្ធភាពនៃការដើរដោយគ្មានឧបករណ៍ជំនួយ។

ជួនកាលកុមារឈរក្នុងលក្ខណះត្រគាកនិងជង្គង់បត់ នេះក៏ព្រោះតែប្រអប់ជើងបត់ឡើងវិញខ្លាំងពេក។ បែបនេះធ្វើអោយត្រគាកនិងជង្គុយជាប់សន្ទាក់។





**រណបក្រោមជង្គុងទំហំស្រាល** ដែលពាក់បានតឹងល្មមហើយកុមារអាចឈរបានត្រង់ល្អដើរបាន និងបង្ការការគាំងសន្ទាក់។

> **សូមកុំអោយកុមារធាត់ពេក**
>
> ដោយសារតែជើង និងប្រអប់ជើងរបស់កុមារដែលគមខ្ទងពីកំណើត មានសភាពខ្សោយសំខាន់សូមកុំអោយកុមារមានទំងន់ធ្ងន់ពេក។ ទោះបីកុមារមិនអាចដើរបានក៏ដោយ ការបន្លាស់ទីគឺងាយស្រួលណាស់ប្រសិនបើកុមារមិនធាត់។ សូមលើកទឹកចិត្តកុមារឱ្យបរិភោគ អាហារសំបូរទៅដោយអាហារូបត្ថម្ភ ប៉ុន្តែជៀសវាងអាហារដែលមានបរិមាណជាតិស្ករច្រើន អាហារដែលសំបូរទៅដោយជាតិខ្លាញ់ និងភេសជ្ជៈជាតិផ្អែមពេក។

## ការជួយកុមារអោយវិវត្តទៅមុខ

កុមារភាគច្រើនដែលគមខ្វិនពីកំណើត ពិចង្កេះចុះក្រោមកំរើកមិនរួច ។ ទោះជាពិការភាពក៏ដោយ សំខាន់ត្រូវធ្វើអោយកុមារលូតលាស់ផ្នែករាងកាយ ផ្លូវចិត្ត និងសមត្ថភាពរស់នៅប្រចាំថ្ងៃ អោយបានច្រើនដែលអាចធ្វើទៅបាន។ ឧបករណ៍ៈ សំរួលត្រឹមត្រូវអាចប្រើបាន ដើម្បីជួយកុមារដែលកំរើករាងកាយមិនរួច មានការលូតលាស់ទៅតាមដំណាក់កាល ដូចកុមារធម្មតាដែលមានអាយុស្របាលៗគ្នា។ ចំពោះការកំពុងឆ្លងកាត់នូវដំណាក់កាលដំបូងនៃការលូតលាស់ រាងកាយ សំខាន់គឺវាអាច ...

| | មើលទៅមុខត្រង់ | អង្គុយដោយដៃនៅទំនេរ | វារករបស់ជុំវិញខ្លួន | ឈរដោយដៃនៅទំនេរ | អង្គុយ ឈរ និងដើរ |
|---|---|---|---|---|---|




| មើលទៅមុខត្រង់ | អង្គុយដោយដៃនៅទំនេរ | វារករបស់ជុំវិញខ្លួន | ឈរដោយដៃនៅទំនេរ | អង្គុយ ឈរ និងដើរ |
|---|---|---|---|---|
| ប្រសិនបើនាងមិនអាចងើបមុខដើម្បីអាចមើលឃើញនូវអ្វីដែលកំពុងតែកើតឡើងនៅពីមុខនាង ចូរអោយដេកផ្កាប់នៅលើស្នៀត ឬរៀបជាក្រដាសកាតុង ឬប្រអប់ដែលនាងអាចអង្គុងផ្អែក និងខ្នងរបស់នាងបាន | អ្នកអាចធ្វើកៅអីអំពីធុងចាស់ៗ ឬពីវត្ថុផ្សេងៗទៀតដែលនាងអាចលេងនិងអង្គុយបាន។ | អ្នកអាចធ្វើកូនរទេះតូចដែលអាចជួយអោយរំកិលទៅមុខបាន។ រទេះមានដងកាន់សំរាប់អ្នកដទៃជួយរុញ ។ | ធ្វើគ្រោងឈរដែលអាចទ្រនាងអោយឈរបាន។ ទ្រទំហំខ្លួនទាំងមូលរបស់នាងឡើងលើនៅលើជំហរជើងដែលអាចធ្វើអោយឆ្អឹងមានភាពរឹងមាំ ធ្វើដូចនេះឆ្អឹងនឹងមិនងាយបាក់ទេ។ | នាងអាចទ្រខ្លួននាងឡើងលើធ្វើដូចនេះនាងអាចដើរជាមួយឈើច្រត់។ វាជួយបានប្រសិនបើរណបមានប្រដាប់ទប់ត្រគៀក និងជង្គង់ ដូចនេះនាងអាចអង្គុយចុះបាន។ |

នៅពេលធ្វើឧបករណ៍ជំនួយសំរាប់កុមារគមខ្វិនពីកំណើត ចូរចងចាំថា កុមារម្នាក់ៗមានភាពខុសៗគ្នា។ កុមារខ្លះអាចដើរដោយមិនចាំបាច់ប្រើរណប ប្រហែលគេអាចដើរតាម បង្កាន់ដៃពីរស្របគ្នាដូចមានក្នុងរូបនេះហើយបន្ទាប់មកអោយគេប្រើឈើច្រត់។



បញ្ហាផ្សេងទៀត រណបលើជង្គង់ ឬរណបក្រោមជង្គង់។ ចំពោះកុមារផ្សេងទៀតត្រូវការរទេះរុញ។



កុមារនេះមានបញ្ហាគមខ្វិនពីកំណើត នាងបានរៀនដើរដោយប្រើប្រាស់ជើងច្រត់ទប់នឹងកែងដៃដែលសំរួលទៅតាមប្រភេទរបស់អ្នកដើរ។ រាងកាយ និងឧបករណ៍មានលក្ខណៈស្មើគ្នានិងទប់ខ្លួនបានត្រូវបានកែលំអ។ ជំនួយជួយដល់ឈើច្រត់ត្រូវយកបន្តិចម្តងៗ រហូតដល់នាងអាចដើរជាមួយឈើច្រត់បាន។

## ការវះកាត់ និងកែខែរាងកាយ

ដើម្បីបង្ការ ឬកែលំអ**ការជាប់សន្លាក់ជើង** ចំពោះកុមារភាគច្រើន ចាំបាច់ត្រូវពង្រឹងប្រអប់ជើង ទៅតាមវិធីដូចជើងខ្វេរផងដែរ។ ធ្វើដូចនេះការគាំងសន្លាក់មិនកើតឡើងម្តងទៀតទេ កុមារចាំបាច់ត្រូវមានលំហាត់ប្រាណ ហើយប្រហែលជាត្រូវប្រើរណបដ័រ យ៉ាងហោចណាស់ប្រើនៅពេលយប់។

ចំពោះការកោងនៃឆ្អឹងជំនី ប្រសិនបើធ្ងន់ធ្ងរ កុមារខ្លះ ចាំបាច់ត្រូវធ្វើការវះកាត់ ឬប្រើរណបដងខ្លួន។

ចំពោះកុមារគមខ្នងពីកំណើត ដែលមាន**ការផ្លាត់ត្រគាកមួយចំហៀង** ជួនកាលការវះកាត់ដើម្បីកែខែគឺមានប្រយោជន៍បំផុត។ ប៉ុន្តែជាទូទៅ ការវះកាត់មិនត្រូវបានគេផ្តល់យោបល់អោយធ្វើទេ ចំពោះកុមារដែលមាន**ការផ្លាត់ត្រគាកទាំងសងខាង** ។ ជាទូទៅពួកគេនឹងដើរបាន ប្រសិនបើត្រគាកខាងឆ្វេងមានការផ្លាត់នោះ- ទង្វើបែបនេះមានលក្ខណះស្មុគស្មាញបន្តិចបន្តួច និងមិនសូវរងការឈឺចាប់ខ្លាំងទេ។

> ***ចូរប្រយ័ត្ន*** : មុនពេលធ្វើការវះកាត់សំរាប់ការកែខែរាងកាយរបស់កុមារដែលគមខ្នងពីកំណើត ដំបូងត្រូវធ្វើការវាយតម្លៃ យ៉ាងល្អទៅលើលទ្ធភាពដែលនាងមាន ឬការដើរ ហើយថា តើការវះកាត់នឹងអាចជួយនាងអោយបានប្រសើរឬយ៉ាងណា។

## ការបង្ការ ដំបៅ និងរបួសធ្ងន់ធ្ងរ

ចំពោះកុមារដែលមានបញ្ហាកាយវិញ្ញាណនៅលើផ្នែកណាមួយនៃរាងកាយ នៅពេលគេធំពេញវ័យ និងមានទំហំធ្ងន់ធ្ងរ នេះនឹងធ្វើអោយកាន់តែគ្រោះថ្នាក់ទៅលើដំបៅ (ដំបៅក្រែ) ដែលនឹងជួយទ្រទំហំ (ភាគច្រើននៅត្រង់គូទ ឬប្រអប់ជើង)។ ដើម្បីជៀសវាងប្រការបែបនេះ :

- ដាក់កុមារអោយដេក និងអង្គុយនៅលើពូក ឬខ្នើយទន់ៗ (ដូចជាកៅស៊ូទន់) ហើយធ្វើការផ្លាស់ប្តូរ ឬត្រលប់ចុះឡើង។
- ពិនិត្យមើលផ្នែកខាងក្រោមនៃខ្លួនរបស់កុមារជារៀងរាល់ថ្ងៃ នៅពេលចេញសញ្ញាណដំបូងនៃការរលាក ឬដំបៅ។ សូមពិនិត្យជាពិសេស ទៅលើត្រគៀក ជង្គង់ និងប្រអប់ជើង។
- នៅពេលកុមារធំពេញវ័យបន្តិច កុមារអាចរៀនពិនិត្យលើខ្លួនរបស់គេដោយខ្លួនឯងជារៀងរាល់ថ្ងៃ ពិសេសលើដំបៅ



***ប្រការគ្រោះថ្នាក់***: ទោះជាបណ្តាលទៅជាគមខ្នងពីកំណើត ឬឃ្លង់ កុមារដែលអាចដើរបាន ប៉ុន្តែពួកគេមិនដឹងថា ជាជើងដែលជាប្រការគ្រោះថ្នាក់ខ្លាំងណាស់ ដូចជាមុត រលាក ដំបៅ ឬផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រអប់ជើង។ ត្រូវណែនាំពួកគេអោយចេះពិនិត្យមើលប្រអប់ជើងរបស់ពួកគេជារៀងរាល់ថ្ងៃ។

លើសពីនេះទៅទៀត ត្រូវប្រាកដថាស្បែកជើងសង្រែក ស្បែកជើង និងរណបជើងត្រូវល្មម ហើយមិនត្រូវអោយមានការប៉ោងលើស្បែក ឬរលាក។



កុមារក្នុងរូបនេះ ដែលគមខ្នងពីកំណើតបានធ្វើអោយមុតប្រអប់ជើង នឹងអំបែងកែវ។ ពីព្រោះការមុតនោះមិនបានធ្វើអោយកុមារនោះឈឺចាប់ឡើយ។ គេមានការធ្វេសប្រហែស ហើយធ្វើអោយក្លាយជាផលប៉ះពាល់ធ្ងន់ធ្ងរ។ ពេលនោះផលប៉ះពាល់អាចនឹងរាលដាលទៅដល់ឆ្អឹងទាំងនៅលើប្រអប់ជើង ហើយវាចាប់ផ្តើមបំផ្លាញប្រអប់ជើង។ ជាលទ្ធផលប្រអប់ជើងមានការខូចទ្រង់ទ្រាយ ហើយនាងអាចបាត់បង់ប្រអប់ជើងនោះ។

> **ចំពោះពត៌មានសំខាន់ៗ** ស្តីពីការបង្ការ និងការព្យាបាលដំបៅក្រែ។ ចាំបាច់ត្រូវអានស្តីពីប្រដាប់ពាក់នៅជើងពិសេស និងវិធីផ្សេងៗនៃការការពារប្រអប់ជើង។

អ្នកនឹងឃើញព័ត៌មានសំខាន់ៗ ដែលទាក់ទងនិងកុមារគមខ្នងពីកំណើត នៅក្នុងជំពូកផ្សេងទៀតនៃសៀវភៅនេះ ជាពិសេសៈ

លើសពីនេះ សូមមើលនៅក្នុងជំពូកស្តីពីការតាំងសន្លាក់ ជើងខ្វេរ លំហាត់ប្រាណ ការលូតលាស់យឺត រណប រទេះរុញ និងកៅអីពិសេស ។



កុមារដែលកើតមកមានដុះសាច់ក្នុងគ្រួសារមួយនៅជនបទដែលក្រីក្រ ពុំមានសមត្ថភាពបញ្ជូនកូនទៅវះកាត់



កុមារ ( **ប្រូជីម៉ូ** ) បានធ្វើកៅអីពិសេសសំរាប់នាងដោយមានដាក់ចានគោមទប់នឹងខ្នងដើម្បីការពារការប៉ះនិងខ្នង



កុមារដែលដុះសាច់ពីកំណើត រៀនដើរជាមួយឧបករណ៍ដើរ ( **ប្រូជីម៉ូ** ) កុមារអាយុ១ឆ្នាំ ដែលមានដុះសាច់ពីកំណើត



ជិះលើរទេះរុញតូច ដែលផលិតដោយបុគ្គលិកពិការម្នាក់ ( **ប្រូជីម៉ូ**)